**ក្រុមហ៊ុន វីហ្សិន ២៦ អប់ធីខលមេនូហ្វេកឆឺរីង (ខេមបូឌា) លីមីធីត**
VISION 26 OPTICAL MANUFACTURING (CAMBODIA) LIMITED

# កិច្ចព្រមព្រៀង

## រវាង

## ក្រុមហ៊ុន វីហ្សិន ២៦ អប់ធីខលមេនូហ្វេកឆឺរីង (ខេមបូឌា) លីមីធីត
## និង តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋាន
## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២៥ វេលាម៉ោង ០៩:៣០នាទី នៅ **ក្រុមហ៊ុន វីហ្សិន ២៦ អប់ធីខលមេនូហ្វេកឆឺរីង (ខេមបូឌា) លីមីធីត** មានទីតាំង ភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានកិច្ចប្រជុំរវាងនាយកក្រុមហ៊ុន និងតំណាងកម្មករ និយោជិត និងសហជីពមូលដ្ឋានប្រចាំក្រុមហ៊ុន។

នៅក្នុងកិច្ចប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមថា ដោយសារតែក្រុមហ៊ុន មានការធ្លាក់ចុះនូវការបញ្ជាទិញ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសរុបចំនួន **២៥នាក់** (ស្រី២០នាក់) ក្នុងចំណោមនិយោជិតសរុបទាំងអស់ ៥២៧ (ស្រី៣៤៤នាក់)មានរយៈពេលចំនួន**៦១ថ្ងៃ** គឺចាប់ពី**ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥**។ នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ កម្មករ និយោជិតបានឯកភាពទទួលយកប្រាក់ឧបត្ថម្ភពីក្រុមហ៊ុនចំនួន ៣០ដុល្លារ (សាមសិបដុល្លារ) សម្រាប់កម្មករនិយោជិតម្នាក់ៗ។ ប្រាក់ឧបត្ថម្ភនេះក្រុមហ៊ុនបើកជូនកម្មករនិយោជិតចំនួន ១៥ដុល្លារ (ដប់ប្រាំដុល្លារ) នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០២៥ និងចំនួន ១៥ ដុល្លារ (ដប់ប្រាំដុល្លារ) នៅថ្ងៃ ១០ ខែមិថុនា ឆ្នាំ២០២៥។ ប្រាក់ឧបត្ថម្ភនេះបានបូកសរុបថ្លៃធ្វើដំណើរ ៧ដុល្លារ (ប្រាំពីរដុល្លារ) និងថ្លៃស្នាក់នៅ (បើមាន)។

អង្គប្រជុំបានចប់វេលាម៉ោង ១០និង០០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និងសហការគ្នាយ៉ាងរលូន។

ថ្ងៃច័ន្ទ ១១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
សៀមរាប, ថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០២៥

**ស្នាមមេដៃប្រតិភូបុគ្គលិក**

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
វីហ្សិន 26 អប់ធីខល មេនូហ្វេកឆឺរីង (ខេមបូឌា) លីមីធីត
Vision 26 Optical Manufacturing (Cambodia) Limited
KINGDOM OF CAMBODIA

CHU LAI LEE